# ចណ្ឌេស្វរ

ចណ្ឌេស្វរ គេស្គាល់ថាគឺជាការបង្ហាញព្រះសិវក្នុងទម្រង់ជាកំហឹង ដ្បិតពាក្យថា "ចណ្ឌ" ជាភាសាសំស្រ្កឹតមានន័យថា "កាច, ក្តៅ, ក្រោធ, ខឹង"។ រឿងរ៉ាវទាក់ទងនឹងចណ្ឌេស្វរ មានរៀបរាប់នៅក្នុងគម្ពីរបេរិយបុរាណ (Periyapurâṇa) និទានថា "ចណ្ឌេស្វរ ជាកូនប្រុសក្នុងត្រកូលព្រាហ្មណ៍ម្នាក់ដែលគេស្គាល់ឈ្មោះមួយទៀតថា **"វិសរសម៌ន"** (Visarasarman) ដែលជាក្មេងម្នាក់មានចិត្តអាណិតស្រឡាញ់សត្វគោ និងតែងតែថែទាំគោជាប្រចាំ។ មានពេលមួយ វិសរសម៌ន បានយកទឹកដោះគោទៅស្រោចលើលិង្គព្រះឥសូរមួយដែលខ្លួនបានធ្វើពីដីខ្សាច់ ដែលធ្វើឱ្យឪពុកក្មេងនេះឈ្មោះថា ដត្ត (Datta) ខឹងនិងស្តីបន្ទោសកូនរបស់គាត់យ៉ាងខ្លាំង ដ្បិតវិសរសម៌នបានប្រើប្រាស់ទឹកដោះគោខ្ជះខ្ជាយ។ អំឡុងពេលស្តីបន្ទោស វិសរសម៌ន កំពុងតែស្ងឹងស្ងាធនៅមុខលិង្គធ្វើអំពីដីខ្សាច់ ហើយមិនឃើញឪពុកខ្លួនស្តីបន្ទោសឡើយ ដែលនាំឱ្យឪពុករបស់គាត់ខឹងកាន់តែខ្លាំងរហូតទាត់សិវលិង្គធ្វើពីដីខ្សាច់នោះចោល។ ការសមាធិរបស់វិសរសម៌នបានបរាជ័យ ធ្វើឱ្យគេខឹងឪពុករបស់ខ្លួនខ្លាំង ក៏វាយឪពុកមួយដំបង។ ពេលនោះដំបងរបស់គេបានក្លាយទៅជាពូថៅមួយរហូតធ្វើឱ្យដាច់ជើងដត្តដែលត្រូវជាឪពុក។ ព្រះសិវឃើញដូច្នោះ ក៏បានប្រទានពរទៅឪពុករបស់វិសរសម៌ន និងបានតជើងរបស់គាត់ឱ្យដូចដើមឡើងវិញ។ ដោយព្រះសិវឃើញពីភាពលះបង់យ៉ាងធំធេងរបស់វិសរសម៌ន ឬចណ្ឌេស ព្រះសិវក៏បានប្រទានពរឱ្យទៅចណ្ឌេសធ្វើជាអ្នកថែរក្សារាល់ទ្រព្យសម្បត្តិរបស់ទ្រង់ ម្ល៉ោះហើយទើបគេឃើញនៅតណ្ឌាខាងត្បូងគេនិយមឆ្លាក់រូបទេពចណ្ឌេស្វរធ្វើជាទ្វារបាលនៅខាងមុខប្រាសាទដែលឧទ្ទិសដល់ព្រះឥសូរ ដែលបង្ហាញជារូបទេពកាន់ពូថៅមួយក្នុងព្រះហស្ត (រូបលេខ១)។[១] ក្រោយមក គេឃើញមានប្រាសាទមួយចំនួននៅតណ្ឌាសាងឡើងដើម្បីឧទ្ទិសដល់អាទិទេពចណ្ឌេស្វរតែម្តង ដ្បិតគេយល់ថា ទ្រង់គឺជាការបែងភាគមួយរបស់ព្រះសិវ។

ដោយឡែក នៅក្នុងអារ្យធម៌ខ្មែរសម័យបុរាណវិញ ខ្មែរបានស្គាល់ព្រះនាមទេពអង្គនេះដូចគ្នា។ ដ្បិត ព្រះនាមចណ្ឌេស្វរ គេប្រទះឃើញនៅក្នុងអត្ថបទសិលាចារឹកយ៉ាងតិចពីរ គឺទីមួយសិលាចារឹកព្រះធាតុបាដើម ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង (K.360) (រូបលេខ២) និងសិលាចារឹកវត្តពោធិ ខេត្តតាកែវ (K.22) (រូបលេខ៣) ដែលសិលាចារឹកទាំងពីរនេះសុទ្ធសឹងមានអាយុកាលនៅ ស.វ.ទី៧ដូចគ្នា។ សិលាចារឹកនៅប្រាសាទព្រះធាតុបាដើម សព្វថ្ងៃរក្សាទុកនៅឃ្លាំងមន្ទីរ

[១] (1) Rajarajan 2019: 157-195.

វប្បធម៌ និងវិចិត្រសិល្បៈខេត្តស្ទឹងត្រែង បានចារឹកព្រះនាមទេពអង្គនេះនៅក្នុងគាថាទី៤ បន្ទាត់ទី៧ (ជាភាសាសំស្ក្រឹត) ដែលពីគាថាដំបូងមកគេរៀបរាប់ពីការថ្វាយបង្គំព្រះសិវ និងរៀបរាប់អំពីកក្តីភាពរបស់ចន្ទ្រវិន្នៅដែលបានកសាងប្រាសាទធ្វើអំពីថ្មតម្កល់ "**ព្រះចណ្ឌេស្វរ**"។[២] ត្រង់ចំណុចនេះ យើងពិបាកសន្និដ្ឋានបានថា "ព្រះចណ្ឌេស្វរ" ដែលគេរៀបរាប់នេះជាព្រះនាមរបស់សិវលិង្គ ឬយ៉ាងណា ព្រោះមានសិលាចារឹកមួយផ្ទាំងទៀតចារឹកជាភាសាខ្មែរ រកឃើញនៅទីនោះដូចគ្នា ចុះបញ្ជីលេខ K.1257 បានរៀបរាប់អំពីការធ្វើអំណោយរបស់ម្ចាស់បុណ្យថ្វាយដល់ព្រះ "**ស្រីសុវណ្ណេស្វរ**" (Śrîsuvarṇṇeśvara) (រូបលេខ២៤)។ ប៉ុន្តែ បើទោះបីជា "ចណ្ឌេស្វរ" ពុំមែនជាព្រះនាមសិវលិង្គក៏ដោយ ក៏អាចគេចង់សំដៅទៅលើព្រះសិវក្នុងទម្រង់ជាថែរក្សាទ្រព្យសម្បត្តិរបស់ប្រាសាទដូចគ្នា។ សព្វថ្ងៃ ប្រាសាទបាដើម បានបាក់បែកស្ទើរអស់ទៅហើយ ពោល នៅសល់តែក្លោងទ្វារប៉ុណ្ណោះដែលនៅមានរូបរាងឈរ (រូបលេខ២៥) ហើយក្រៅពីផ្តែរទ្វារនិងសសរពេជ្រដែលគេទុកនៅទួលប្រាសាទ គេធ្លាប់រកឃើញបដិមាគោនន្ទិ សិវលិង្គ និងបំណែកទេវរូបសល់ត្រឹមព្រះបាទ និងបំណែកដងខ្លួនតិចតួច (រូបលេខ២៦-៧)។ ដូច្នោះហើយ យើងពុំអាចដឹងថាតើព្រះចណ្ឌេស្វរដែលគេរៀបរាប់នៅក្នុងសិលាចារឹកនេះ មានរូបស្នងជាសិវលិង្គ ចម្លាក់ ឬបដិមាឱ្យបានប្រាកដឡើយ។

ចំណែកឯ សិលាចារឹកវត្តពោធិ៍ ខេត្តតាកែវ (សព្វថ្ងៃនៅសារមន្ទីរហ្គីមេ ប្រទេសបារាំង) វិញ បន្ទាត់ដំបូងៗគេនិយាយពោលសរសើរអំពីអានុភាពរបស់ព្រះសិវនិងវិស្ណុ ដោយហៅព្រះនាមទ្រង់ថា "ហរ" (សិវ) និង "អច្យុត" (វិស្ណុ)។ ឃ្លាបន្តទៀតគេពោលសរសើរអំពីអានុភាពព្រះបាទស្រីឦសានវរ្ម័នទី១ ហើយពាក្យបន្តទៀតគេបានរំលេចពីនាមអ្នកធ្វើអំណោយឈ្មោះ "ឦសានទត្ត" ត្រូវជាខ្សែរាជវង្ស ដែលទ្រង់បានកសាងបដិមាព្រះអាទិទេពពីររួមបញ្ចូលគ្នាគឺ "សន្ករ" (សិវ) និង "អច្យុត" (វិស្ណុ)។ ជាពិសេសនោះ នៅបន្ទាត់ទី៩ គេបានចារឹកថា "វិស្ណុចណ្ឌេស្វរេសាន លិង្គំតេន ប្រតិស្ឋិតំ" ដែលលោក Auguste Barth យល់ថាជារបៀបមួយដែលគេកសាងលិង្គមួយរួមបញ្ចូលគ្នារវាងទេពពីរ គឺ "វិស្ណុ" និង "ចណ្ឌេស្វរេសាន" (សិវ) ។ ប៉ុន្តែក្រោយមកលោក Goerge Coedès បានបដិសេធ និងបានសន្និដ្ឋានថា ទំនងជាការបង្ហាញលិង្គដែលមានទេពបីរួមបញ្ចូលគ្នា គឺ "វិស្ណុ", "ទេវី" (ទេពស្រី) និង "សិវ"។[៣] ដូច្នេះ មានន័យថា ទោះបីអ្នកប្រាជ្ញទាំងពីររូបមានគំនិតស្ទើរៀងៗខ្លួន

---

[២] (2) Coedès 1953: 61.

[៣] (3) Coedès 1951: 145; Barth 1885: 50.

យ៉ាងណាក៏ដោយ ក៏អ្នកទាំងពីរបានយល់ស្របដូចគ្នាថា "ចណ្ឌេស្វរ" គឺជាទម្រង់មួយរបស់ព្រះសិវ (ឥសូរ)។

ជារួមមក អត្ថបទនេះគ្រាន់តែចង់បង្ហាញថា ទោះបីរឿងរ៉ាវដែលទាក់ទងនឹង "ចណ្ឌេស្វរ" ដែលជារូបភាពមួយនៃព្រះឥសូរដែលឥណ្ឌាមិនសូវពេញនិយមក៏ដោយ ក៏ខ្មែរនៅជំនាន់ស.វ.ទី៧ ស្គាល់រឿងនេះ និងបានលើកយកមករៀបរាប់ក្នុងសិលាចារឹកដូចបង្ហាញទាំងពីរខាងលើ។ អ្វីដែលគួរកត់សម្គាល់បន្ថែមពីសេចក្តីខាងលើនោះគឺ សិលាចារឹកទាំងពីរដែលបានរៀបរាប់សុទ្ធតែចារឹកនៅស.វ.ទី៧ ប៉ុន្តែមកដល់សម័យអង្គរ រវាងស.វ.ទី១០-១២ គេបានកសាងសិវលិង្គដែលមានព្រះភក្ត្រនៅផ្នែកខាងលើ (មុខលិង្គ) យកមកតម្កល់នៅទេវស្ថានទាំងពីរដូចគ្នា (ប្រាសាទបាដើម និងប្រាសាទវត្តពោធិ៍) (រូបលេខ៨-៩) តែយើងមិនដឹងអត្ថន័យឱ្យជាក់យ៉ាងណានោះឡើយ ថាហេតុដូចម្តេចបានជាគេសាងលិង្គថ្មីមានមុខមកដាក់កន្លែងទាំងពីរនេះដូចគ្នា?

## ឯកសារយោង


**Auguste, Barth**

1885, *Inscriptions Sanskrit du Cambodge*, Paris

**Coedès, G.**

1951, *Inscription du Cambodge*, Tome III, Hanoi

1953, *Inscription du Cambodge*, Tome V, Hanoi

**Rajarajan, R.K.K.**

2019, 'Caṇdikeśvara myth and transformation: violence and reconciliation', *Indologica Taurinensia: The journal of the international association of the Sanskrit studies,* Torino


AMS អរិយធម៌ខ្មែរ KHMER CIVILIZATION



រូបលេខ១៖ បដិមាចណ្ឌេស្វរនៅស្រុកឥណ្ឌា (រូបថត៖ Wikipedia)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៖ ក្រដាសផ្តាមសិលាចារឹកវត្តបាដើម (ផ្តិតដោយ៖ កំ វណ្ណារ៉ា)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៣៖ ក្រដាសផ្តាមសិលាចារឹកវត្តពោធិ ខេត្តតាកែវ (ផ្តិតដោយ៖ EFEO)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៤៖ ក្រដាសផ្តាមសិលាចារឹកវត្តពោធិ ខេត្តតាកែវ (ផ្តិតដោយ៖ EFEO)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៥៖ ប្រាសាទបាដើម (ស្ថានភាពបច្ចុប្បន្ន) (រូបថត៖ កុំ រតនៈពិសិដ្ឋ)



រូបលេខ៦៖ បដិមាគោនន្ទិនៅប្រាសាទបាដើម ស.វ.ទី៧ (រូបថត៖ កុំ រតនៈពិសិដ្ឋ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៧៖ លិង្គស.វ.ទី៧ នៅប្រាសាទបាដើម (រូបថត៖ កុំ រតនៈពិសិដ្ឋ)




រូបលេខ៨.៩៖ មុខលិង្គនៅប្រាសាទបាដើម និងប្រាសាទវត្តពោធិ (ប្រភព៖ Parmentier, 1935 ; Helen, 2006)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី